# ACRA's Newsletter

## December, 2017

## ប្រធានបទ៖ កិច្ចប្រជុំស្តីពី "ការធ្វើលិខិតធ្វើដំណើររបស់ពលករ" និង " ការធ្វើបច្ចុប្បន្នភាពនៃការបើកទីផ្សារ ក្នុងការបញ្ជូនពលករទៅប្រទេសម៉ាឡេស៊ី"

ថ្ងៃទី០២ រោច ខែ មិគសិរ ឆ្នាំ រកា ព.ស ២៥៦១ ត្រូវនឹង ថ្ងៃ០៥ ធ្នូ ឆ្នាំ២០១៧ នៅសាលប្រជុំរបស់សមាគមអាក្រា



សមាគមអាក្រាបានរៀបចំកិច្ចប្រជុំមួយ ជាមួយសមាជិករបស់ខ្លួន ស្តីពី "ការធ្វើលិខិតធ្វើដំណើររបស់ពលករ" និង "ការធ្វើបច្ចុប្បន្នភាពនៃការបើកទីផ្សារ ក្នុងការបញ្ជូនពលករទៅប្រទេសម៉ាឡេស៊ី" ។



លោកជំទាវឧកញ៉ា **អ៊ឹង ស៊ាងរិទ្ធី** ប្រធានសមាគមអាក្រា បានមានប្រសាសន៍ថា ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងមហាផ្ទៃ គ្រោងនឹងបង្កើតតំបន់(ហប្ស)ចំនួន ០៣កន្លែង សម្រាប់ផ្តល់ភាពងាយស្រួលក្នុងការធ្វើលិខិតធ្វើដំណើរសម្រាប់ពលករទៅធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍។ ចំពោះទីតាំងទាំងនោះរួមមាន ក្រុងប៉ោយប៉ែត បាត់ដំបង និង



ភ្នំពេញ(ផ្សារទំនើបស្ទឹងមានជ័យជាន់ទី២)។បន្ថែមពីនេះ លោកជំទាវឧកញ៉ាប្រធាន ក៏បានបញ្ជាក់អំពីរយៈពេលនៃការធ្វើ លិខិតធ្វើដំណើរនេះ រួមជាមួយនឹងឯកសារភ្ជាប់មួយចំនួនផងដែរ។

ចំពោះការបើកទីផ្សារម៉ាឡេស៊ីវិញ លោកជំទាវឧកញ៉ា **អ៊ឹង ស៊ាងរិទ្ធី** បានមានប្រសាសន៍បន្ថែមថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលដឹកនាំដោយ**ឯកឧត្តម សេង សក្ដា** អគ្គនាយកនៃនាយកដ្ឋានការងារ បានធ្វើដំណើរទៅប្រទេសម៉ាឡេស៊ី ក្នុងគោលបំណងប្រជុំពិភាក្សា និងចុះអនុសារណៈនៃកិច្ចព្រមព្រៀង រវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាមួយនឹងសមាគមនៅម៉ាឡេស៊ីកាលពីថ្ងៃទី ២៩-៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ។ ម្យ៉ាងទៀត **លោកជំទាវឧកញ៉ាប្រធាន** បន្តទៀតថា ទីភ្នាក់ងារជ្រើសរើសឯកជនណាក៏ដោយ គឺមានសិទ្ធិបញ្ជូនពលករបានដូចគ្នា ឲ្យតែមានអាជ្ញាប័ណ្ណបញ្ជូន ក៏ប៉ុន្តែដៃគូរបស់ទីភ្នាក់ងារជ្រើសរើសឯកជននៅប្រទេសម៉ាឡេស៊ី ត្រូវចុះឈ្មោះចូលជាសមាជិករបស់សមាគមនៅប្រទេសម៉ាឡេស៊ីជាមុនសិន។ ចំពោះក្រុមហ៊ុនដែលមានបំណងចង់បញ្ជូនពលករ

ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី គឺត្រូវយកអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុនជាដៃគូ មកសុំអាជ្ញាប័ណ្ណទទួលពលករពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈជាមុនសិន ទើបអាចបញ្ជូនពលករបាន ។

## ប្រធានបទ៖ ទិវាប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស

រសៀលថ្ងៃ ៩ រោច ខែ មិគសិរ ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ នៅសាលមហោស្រពកោះពេជ្រ

ក្រុមប្រឹក្សាភិបាលសមាគមអាក្រា និងសមាជិក បានអញ្ជើញចូលរួមអបអរទិវាប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០១៧ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគជបជ ។ ចំពោះគោលបំណងនៃការប្រារព្វពិធីនេះ គឺជាយុទ្ធនាការរួមបង្កើតនូវប្រព័ន្ធសុវត្ថិភាព និងពង្រឹងការអនុវត្តច្បាប់អោយកាន់តែរឹងមាំ សម្រាប់ការពារប្រជាពលរដ្ឋអោយរួចផុតពី ភាពរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលជាធនធានដ៏មានសក្តានុពលក្នុងការពង្រឹង និងពង្រីកខឿនសេដ្ឋកិច្ចដ៏ល្អប្រសើរ ដើម្បីបោះជំហានទៅមុខ ឆ្ពោះទៅកាន់ចក្ខុវិស័យរួមគឺ "**កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ**"។









## <u>ប្រធានបទៈ ពិធីអបអរសាទរគម្រប់ខួប១០ឆ្នាំ នៃសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (អាក្រា)(២០០៧-២០១៧)</u>

ថ្ងៃ ១២ រោច ខែ មិគសិរ ព.ស ២៥៦១ ត្រូវនឹងថ្ងៃ ទី១៥ ខែធ្នូ ឆ្នាំ២០១៧ នៅភោជនីយដ្ឋាន ឡេប្រទីហ្វាង







សមាគមអាក្រា បានរៀបចំ ពិធីអបអរសាទរគម្រប់ខួប ១០ ឆ្នាំ នៃសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា(អាក្រា) (២០០៧-២០១៧) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានការអញ្ជើញចូលរួមពីសំណាក់ស្ថាប័នពាក់ព័ន្ធ បណ្តាអង្គការអន្តរជាតិនានា និងសមាជិករបស់សមាគមអាក្រាផងដែរ។ ឆ្លៀតក្នុងឱកាសនេះផងដែរ លោកជំទាវឧកញ៉ា **អ៊ឹង ស៊ាងរិទ្ធី** ប្រធានសមាគមអាក្រា បានមានប្រសាសន៍ថា សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា បានវិវត្តន៍ខ្លួនយ៉ាងខ្លាំងក្នុងរយៈពេលកន្លងមកនេះ ដោយសមាគមបានសហការជាមួយក្រសួងពាក់ព័ន្ធនានា រួមមាន ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្ថានទូតប្រទេសទទួល និងជាពិសេសមានទំនាក់ទំនងល្អជាមួយក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ ។ សមាគមបានសហការជាមួយអង្គការជាតិ អន្តរជាតិនានាដូចជា អង្គការអន្តរជាតិ ILO IOM UNWOMAN WINROCK UNACT ។ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈបានមានប្រសាសន៍ថា **ឯកឧត្តមបណ្ឌិត** បានជំរុញឲ្យទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ ត្រូវយកចិត្តទុកដាក់ការពារពលករដែលកំពុងធ្វើការនៅក្រៅប្រទេស ដើម្បីអោយពួកគេទទួលបានភាពកក់ក្តៅដូចដែលកំពុងធ្វើការ នៅប្រទេសដើមកំណើត ។ **ឯកឧត្តមបណ្ឌិត** បន្តថា ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវចេះលើកទឹកចិត្តដល់ពលករ ចេះគោរពដល់ពលករ ដែលធ្វើការនៅក្រៅប្រទេស ព្រោះថាពួកគាត់មិនមែនទៅធ្វើជាខ្ញុំគេ ទៅធ្វើជាកញ្ជះដាច់ថ្លៃនោះទេ គឺពួកគេបានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការជម្រុញអោយសេដ្ឋកិច្ចជាតិមានការរីកចម្រើន។ បច្ចុប្បន្ននេះមានពលករខ្មែរ កំពុងបម្រើនៅក្រៅប្រទេសចំនួនប្រហែល ១លាន២សែននាក់ ដោយក្នុងមួយឆ្នាំៗ ពួកគាត់បានផ្ញើប្រាក់មកអោយក្រុមគ្រួសារនៅកម្ពុជាវិញប្រមាណ ៣៨០០លានដុល្លារអាមេរិច។ ទំហំទឹកប្រាក់នេះមិន



ត្រឹមតែលើកស្ទួយដល់ជីវភាពរស់នៅនៅក្នុងក្រុមគ្រួសារពលករប៉ុណ្ណោះទេ ថែមទាំងចូលរួមចំណែកធ្វើអោយសេដ្ឋកិច្ចជាតិមានការរីកចម្រើនផងដែរ។







# ACRA’s Board Profile



Name : Ung Seangrithy

ACRA’s Position : President

Company’s Position : President of UNG RITHY GROUP CO., LTD



Name : Nhek Sothear

ACRA’s Position : Vice-President

Company’s Position : President of SKMM INVESTMENT GROUP CO., LTD



Name : Ken Sorphornrith

ACRA’s Position : General Secretary

Company’s Position : Vice-President of SOK CHAMNOL CO., LTD



Name : Lim Vouchna

ACRA’s Position : General Treasurer

Company’s Position : President of C D M TRADING MANPOWER CO., LTD



Name : Seng Settychey

ACRA’s Position : Auditor

Company’s Position : President of AP TSE &C CAMBODIA RESOURCE CO.,LTD

# ACRA’s Secretariat Profile



Name : Pin Vireak
Position : Executive Director



Name : Danh Engkakada
Position : Advisor



Name : Sen Pisethdanyta
Position : Advisor



Name : Sin Kaomeng
Position : Legal Support/Admin



Name : Ken Panha
Position : Administrative Assistant